# ចម្រៀងអនុស្សាវរីយ៍



# រស់ សេរីសុទ្ធា



CEDORECK
Nº 61

CEDORECK

សម្លេងនាងដក់ជាប់ក្នុងអារម្មណ៍ខ្មែរជានិច្ច

ព.ស. គ.ស. ១៩៧០?

# ប៉ែន រ៉ន



អ្នកចម្រៀងសម្លេងសារិកាមាស

# ស៊ីន ស៊ីសាមុត



អ្នកចម្រៀងដ៏ល្បីល្បាញក្នុងប្រទេសកម្ពុជា

# ហួយ មាស



សម្លេងប្រជាប្រិយសណ្ដាំដួងចិត្ត

# ស្ទឹងស្នេហា

បទភ្លេងបរទេស — សម្រួលតន្ត្រីដោយ : **សម សាមន**

ទំនុកច្រៀង : **ញ៉ែម ផុន** — ច្រៀងដោយ : **ហួយ មាស**

១— **Bengavan** *Solo* ទឹកហូរឆ្ងាយសន្ទឹម ឆ្ងាយផុតក្ដីសង្ឃឹម ឆ្ងាយ
ភក្ត្រ ប៉ប្រឹម ធ្លាប់ ញញឹមរាល់ថ្ងៃ ។

២— ឆ្ងាយទាំងពាក្យផ្ដែផ្ដាំ អូនព្រាត់ព្រោះកម្មចង្រៃ តែធ្វើម្ដេចនិស្ស័យ
ចែកស្នេហ៍ប្រុសថ្លៃ ព្រាត់ពីស្រីឥតស្រណោះ ។

បន្ទរ– **ឱ! Bengavan Solo** អើយ អូនឃ្លាតអ្នកហើយ ឃ្លាតទាំងឈ្មោះ
ឃ្លាតទាំងសំដីពាក្យកវីពិរោះ តែចិត្តនៅស្មោះនឹងថ្លៃ ។

៣— ឃ្លាតពីប្រុសតែប្រាណ ចិត្តទាំងម៉ុន្ទានអាល័យ ធ្លាប់រួមរ័ក្សមេត្រី
ប្ដូរចិត្តភក្ដីនឹងរូបស្រី សង្សារ ។

**Boléro–**

B2 B2B4– BB2 IV CoC2 C4C2-CoC4 IV B2 BB2-C4C2-CB2 – B4
CC4– { B2Bo - B2B IV
B2Bo B2Co IV }

R— Co CoCo C2 B4Co- B4 II B4C CoC2 CoC B4B2 IV C2 C2C2
C4 CoC2-B4 IV B4C CoC4-C2C2 IV

# ស្ទឹងស្នេហា

បទភ្លេងបរទេស សម្រួលតន្ត្រីដោយ : **សម សាមន**

ទំនុកច្រៀង : **ញ៉ែម ផុន** ច្រៀងដោយ : **ហួយ មាស**

១— **Bengavan Solo** ទឹកហូរឆ្ងាយសន្សឹម ឆ្ងាយផុតក្តីសង្ឃឹម ឆ្ងាយភក្ត្រ ប៉ប្រឹម ធ្លាប់ ញញឹមរាល់ថ្ងៃ ។

២— ឆ្ងាយទាំងពាក្យផ្តែផ្តាំ អូនព្រាត់ព្រោះកម្មចង្រៃ តែធ្វើម្តេចនិស្ស័យ ចែកស្នេហ៍ប្រុសថ្លៃ ព្រាត់ពីស្រីឥតស្រណោះ ។

បន្ទរ– ន! **Bengavan Solo** អើយ អូនឃ្លាតអ្នកហើយ ឃ្លាតទាំងឈ្មោះ ឃ្លាតទាំងសំដីពាក្យកវីពិរោះ តែចិត្តនៅស្មោះនឹងថ្លៃ ។

៣— ឃ្លាតពីប្រុសតែប្រាណ ចិត្តទាំងមុំន្មានអាល័យ ធ្លាប់រួមរ័ក្សមេត្រី ប្តូរចិត្តភក្តីនឹងរូបស្រី សង្សារ ។

**Boléro**–

B2 B2B4– BB2 IV CoC2 C4C2-CoC4 IV B2 BB2-C4C2-CB2 – B4

CC4– { B2Bo - B2B IV / B2Bo B2Co IV }

R— Co CoCo C2 B4Co- B4 II B4C CoC2 CoC B4B2 IV C2 C2C2 C4 CoC2-B4 IV B4C CoC4-C2C2 IV

# ខ្មៅអើយខ្មៅ




5 5 | 3. 1 2 21 | 6 56 16 53 | 53 21 21 61 | 3 . . 56 |

(3) 1 1 6 53 56 | 33 21 21 61 | 3 . . . 5 5 3.1 2 21 |

6 56 16 53 | 53 21 21 61 | 3 . . 56 | (3) 1 1 6 53 56 | 33 21 21 61 |

3 . . . |

SLOW KRACH. BO C5C2. B5CO CO B5B2 C5 D1D2 D1C5

C2C5 C2CO B5CO B5B2 B5C2 C5D1 B2(3)D2D1 C5 C2C5

D1C2 C2CO B5CO B5B2 B5C2 Ⅲ

# ខ្មៅអើយខ្មៅ

បទភ្លេង-ទំនុកច្រៀង :
**អឹម សុខសឹម**

ច្រៀងដោយ :
**អឹម សុខសឹម និង រស់ សេរីសុទ្ធា**

ផ្ដើម — ខ្មៅអើយខ្មៅ . . .

១— បងថាអូនខ្មៅ ៗ ក្លិត ខ្មៅអូននេះសូមបងកុំគិត មិនមែនខ្មៅចិត្ត ឡើយណា ខ្មៅយ៉ាងនេះចេះសព្វទាំងឡាយយ៉ាង បងអើយនេះ សំណាងអូនសាងមកពីជាតិមុន ។

២— ខ្មៅដូចអូនប៉ិនរកប៉ិនពុន វណ្ណៈអធន ក៏ប៉ុន្តែមាំមួន ស្រឡាញ់ ថ្នមបងឯង ថែថមជាងខ្លួន បានអ្វីក៏ឲ្យមុន បងគង់ដឹងហើយចិត្តខ្មៅ។

៣— ថ្វីបើខ្មៅ តែអូនខ្មៅស្អាត ខ្មៅតែសាច់ ចិត្តមានមាយាទ មិន ដែល ព្យាបាទនរណា ទៅនេះមកនោះ ងូតទឹកជំរះកាយា បង អើយផ្ទួយមើលផងណា តើខ្មៅអូនស្រស់ឬទេ ។

៤— ខ្មៅដូចអូនមិនចេះឈឺផ្ដាស បងមើលឲ្យច្បាស់មានអ្វីគួរឲ្យខឹងទេឬខឹង នឹងអូន ចេះតែដើរ ៗ លេងៗ ហើយចោលបងឯង ចំបែងនៅតែផ្ទះ ។

RUMBA KBACH—

BC4C1C B4CC1C4- C1C4DD2- DC4C1C B4B1B4C1 IV C4DD2D-
C4C1C4D-C1-C4C1 C4D C1-C1CB4B1- { B4C1 II
B4C B4 II }

# កន្ទង់មាស

បទភ្លេង–ទំនុកច្រៀង ៖ ច្រៀងដោយ ៖

ស៊ីន ស៊ីសាមុត រស់ សេរីសុទ្ធា

១- ឱ! សត្វកន្ទង់ៗមាសអើយ (ពីរដង) ហោះព្លួយ ៗ ត្រដឹង សម្លឹង សម្លក់មើលអី មើលផ្កាចំប៉ាឬផ្កានួនស្រី (ពីរដង) កន្ទង់មាសអើយ មើលអី មើលមិនដាក់ភ្នែក ។

២- ខ្ញុំស្រឡាញ់ ៗ ប្រុសក្មេង (ពីរដង) បណ្ដើរគ្នាលេងតាមផ្លូវបំបែក ថ្ងៃស្អែក ៗ ឡើងជួបទៀត ផ្លូវទូលាយ ឬផ្លូវចង្អៀត (ពីរដង) ស្អែក ឡើងជួបទៀត ដើរឲ្យអស់ចិត្ត ។

៣- កន្ទង់មាសអើយចង់ក្រេបផ្កាអី (ពីរដង ផ្កានួនស្រីឬផ្កាប្រលិត អាណិតប្រាប់ឲ្យដឹងផង គ្រាន់ខ្ញុំថែទាំលំអង (ពីរដង) ជូនកន្ទង់បង តាមចិត្តប្រាថ្នា ។

**Saravann —**

A4B B2B4 C C2B2 B4C C2B4 II A4B B2B4 C C2B2 B4C C2B4 II
B2B4 CC2 C4 DoC C2C4 DoC2-CC2C B4B2 CB4 B2B A4- II B
A4A1 - A4B A4B B2A4 II B A4A1- A4B A4B B2B4 B2 B4C C2
C4C2 CB4B2 II

# សំបួរមាស

បទភ្លេងបូរាណ　　　　　សម្រួលតន្ត្រីដោយ : **ហេង ហួរនេ៉ង**

ទំនុកច្រៀង ៖ **ញ៉ែម ផុន**　　　ច្រៀងដោយ ៖ **ស៊ីន ស៊ីសាមុត**

១— សំបួរមាសអើយផ្លែលាក់សន្ទឹក　បងបួសហើយសឹកមកដណ្ដឹងស្រី
(ពីរដង) អក្ខរាបងលាក់ដាក់ក្រោមក្ដារតី　កែវកុំយកប្ដីមុនវស្សវត្ត ។

២— អកកាច់សំបុកកុកលាស់រោមថ្មី　ទំពាំងទូលដីឫស្សីបែកគុម្ព (ពីរដង)
ដាច់ខែអស្សុជកែវពេញក្រមុំ　ផ្ការីកជួបឃ្មុំយំសុំលំអង ។

. . . ភ្លេង . . .

បន្ទរ– ផ្កាផុះតាបផ្លូវរៀមមិនត្រូវការ　ចិត្តគួចប្រាថ្នាផ្កាក្នុងរបង (ពីរដង)
ផ្កាសំបួរមាសមានម្ចាស់គ្រប់គ្រង　ក្រពុំលើទងចាំបងត្រកងថ្នមបី ។

៣— ផ្កាផុះដីក្រុងមានផុងអន្ទាក់　ផ្កាអួចមានធ្នាក់ទាក់ភ្នែកករី (ពីរដង)
ពេលបានឃើញផ្កាដូចបានឃើញស្រី　សូមកែវប្រណីសំដីបងផង ។

**Ream Kbach—**

CC C2C4 BB2 B4C II $C_2$B4 CC2-CC4 $C_2$C $B_2$B4 IV CC

$C_2$C4 BB2 B4C II $C_2$B4 CC2 - CC4 $C_2$C B2B4-$B_2B_2$ - $BB_2$ B4C

B4 B2B II C$C_2$ C4Do - DC4 DC $C_2$C4 IV

# លិញជូមាសបង

SLOW ROCK




3 53 5 63 | 5 - - i 2 | 3 - 03 i6 | 5 - - - |

0 6i 5 6i6 | 5 35i 2 355 | 5 355 5 - | 5 6235 5 - |

33 532 300 | 22 32i 200 | i i i 23 | 2 - i 6 |

5 - 03 25 | 5 - - 656 | 5 3 302 56 | i - - - |

# លិញថ្ងូ មាសបង

បទភ្លេង ៖ **សម សាខន** ច្រៀងដោយ ៖

ទំនុកច្រៀង ៖ **ញ៉ែម ផុន** **ស៊ីន ស៊ីសាមុត**

១— បងលួចមើលស្រីពីចម្ងាយ គួរឲ្យស្តាយ ។ ដាប់ក្នុងចិត្តមើលពីព្រឹក
ដល់យប់ងងឹត ស្នេហ៍ដល់កំរិតចិត្តប្រុសប្រាថ្នា ។

បន្ទរ.- មើលហើយមើលទៀត បងខំឆ្លៀតគន់ភក្ត្រា ស្នេហារីកស្រស់
ដូចផ្កា ឲ្យចិន្តាមានបំណង ហ៊ា ហ៊ា ហ៊ា លិញថ្ងូមាសបង
អាសូររៀមផង ដែលប៉ងលើពៅ ។

២— អូនអង្គុយដេរ ត្បេរបង្អួច ចិត្តបងតួចប្រឹងលួចហួចហៅ អូន
នាងអៀន មិនហ៊ានចេញក្រៅ តើថ្ងៃណាទៅ ទើបពៅមេត្តា ។

បន្ទរ.- សូមអូនអាណិតដល់ដួងចិត្ត ដែលប្រាថ្នា មេត្តាដាក់ទាន
ស្នេហាដល់រៀមរា ណានួនល្អង ហ៊ា ហ៊ា ហ៊ា លិញថ្ងូ មាស
បង អាសូររៀមផង ដែលប៉ងលើពៅ ។

**Slow Rock—**

**B3C B3C C1 B3C II C4 DD1 II DC4 C1C IV C1C4 CC1 C4C4C-**
**B3CBB1-B3C CC- C1C4 B2C III D1 D1D3 D1 DD1-DDD1 DC4D-**
**C4 C4C4 D D1D II C4C1C II B3C1 B3C II C1C C1 D3D1 II**
**DC C1C4 III**

# បងស្រឡាញ់តែអូន

បទភ្លេង៖ **សម សាខន**

ទំនុកច្រៀង៖ **ញ៉ៀម ផុន**

ច្រៀងដោយ៖

**ស៊ីន ស៊ីសាមុត**

១— បងស្រឡាញ់ ៗ តែអូន ស្រឡាញ់ស្ងួនពេញក្នុងចិន្ដា គ្មានបែកបែរ
ប្រែចិត្តសាវា ឬដោះសាររកគូថ្មីឡើយ ។

បន្ទរ— ឲ្យបងដកចិត្តចេញពីស្នេហ៍ម្ដេចបាន បងសូមផ្ញើប្រាណភ្ជាប់និស្ស័យ
ក្នុងលោកនេះបងស្រឡាញ់តែចរណៃ ចិត្តស្មោះភក្ដីតែស្រីមួយ ។

២— បងស្រឡាញ់ ៗ តែអូន សូមស្រីស្ងួនកុំទុក្ខា ។

១— ចិត្តសន្សំខំប្រឹងស្រឡាញ់ សុខចិត្តចាញ់ៗព្រោះស្នេហា ប្រឹងបំរះ
មិនឈ្នះវាសនា សូមចិន្ដាមេត្ដាប្រណី ។

បន្ទរ- ឲ្យបងដកចិត្តចេញពីស្នេហ៍ម្ដេចបាន បងសូមផ្ញើប្រាណភ្ជាប់និស្ស័យ
ក្នុងលោកនេះបងស្រឡាញ់តែចរណៃចិត្តស្មោះភក្ដីតែស្រីមួយ ។

២— បងស្រឡាញ់ៗតែអូន សូមស្រីស្ងួនកុំទុក្ខា ។

**Boléro Lent —**

A2 A2B2 CB4 B2B4 IV B1 B2B4 B1B2 B4A2 IV A2 A2B2 CB4
B2B4 IV B1 B1B1 B1B2 B4B2 IV
R— C CC2 C2Co CD- DoD II C4 C4C4 C4D C4C2 IV C CC2
C2Co CD - DoD II C4 C4C4 C4D C4C2 IV

# ការអូនស្រឡាញ់បង

បទភ្លេង : គែន ឯម — ច្រៀងដោយ :

ទំនុកច្រៀង : ញ៉ែម ផុន — សូ សាវឿន

១— ខែរះព្រាង ៗ អូនដើរកាត់ភ្លៀងស្ទាត់ជួបបង ជួបហើយនិយាយ
ឆ្លើយឆ្លង ពាក្យពេចន៍ផ្ដោះផ្ដងពីរឿងស្នេហា ។

២ - ទឹកលិចប្រៀបស្រែ កាត់ជួបប្រុសស្នេហ៍គូសង្សារ ថ្ងៃចេញវស្សា
ប្រុសស្នេហា ប្រែផាដោះដៃ ។

៣— អូនខំស្រែកហៅ តែប្រុសពៅមិនព្រមចេញស្ដី ភ្លេចអស់នូវចិត្ត
ភក្ដី ដែលរូបស្រី ខំស្រឡាញ់បង ។

៤— ស្រូវស្រែបែកគុម្ព ចំណែករូបខ្ញុំ ឥតមានគូគ្រង ទុក្ខស្រីច្រើនពេក
កន្លង ព្រោះរូបបងឃ្លាតឆ្ងាយពីស្រី ។

**REAM VONG –**

B5B5 CoC2 C5B5 B4E5 CoB5 II B2B4 B5Co B5Co BoB2 B4B2 II
B2B4 B5Co B5B2 BoB2 B1B2 II B2B4 B5Co C2Co BoB2 B4B-B4-
B2Bo A4Bo B2B4 CoB1 BoA4 II

# ឃ្មុំធ្វើសំបុក

BOLERO JERK

F 4/4



6 67 31 61 | 2 . . . | 02 23 26 12 | 6 . . . | 05 56 12 16 |

5 . . 1 | 2 . 3 21 61 | 3 . . . | 2 . 1 23 16 | 1 . . . |

0 3 5 6 | 3 . 5 31 6 | 65 61 21 25 | 3 . . . | 0 3 . 5 7 |

6 . 5 76 3 | 36 56 35 23 | 5 . . . |

# ឃ្មុំផ្ញើសំបុក

បទភ្លេង ៖ ស៊ីន ស៊ីសាមុត    ច្រៀងដោយ :

ទំនុកច្រៀង : ញ៉ែម ផុន    ស៊ីន ស៊ីសាមុត

១— រៀមគេងស្រមៃនឹកថ្ងៃជានិច្ច  អារម្មណ៍មិនភ្លេចពីក្តីស្នេហា  នឹក
ត្រាថ្នាក់ថ្នមបីបមកាយា  វាចាប្អូនផ្អួងចិត្តភក្តី ។

២— ឃ្មុំផ្ញើសំបុកទុកចិត្តបង្គង  ដូចរូបរៀមបងផ្ញើប្រាណនឹងស្រី  ផ្ញើក្លិន
ផ្ញើខ្លួន  ផ្ញើព្រេងនិស្ស័យ  យប់ថ្ងៃអ្វី ៗ រៀមផ្ញើទាំងអស់ ។

បន្ទរ— រាត្រីបង្អើយគេងកើយភ្លៅស្រី គេងស្តាប់សំដី គួរឲ្យស្រណោះ គេង
ស្តាប់ចម្លើយយប់ក្រោយបង្អស់ គេងមើលសម្រស់សម្ផស្សសង្សារ ។

៣— ស្នេហ៍ប៉ុណ្ណឹងហើយម្តេចឡើយអូនឆ្ងល់  ថាបងមានគលហ៍ចង់តែ
សារា  ថ្ងៃនេះយើងបែកថ្ងៃស្អែកជួបគ្នា  ជួបគ្រប់វេលាលុះត្រា
អវសាន្ត ។

Boléro Twist —

C4C4 DC B2B B2B4 IV B4B4 CB4 BB2 B4B IV A2A2 BB2
B4B B2A2 II B2B4- { CB4 B2B B2C IV
B2B4 CB2 BB2 IV }

R — CC2 C4C- C2C B2B- A2B B2B4 B2B4 C4C IV CC2 DC4-
C2D C4C-C4C2 C4C C2B4 CC2 IV

# ចិត្តស្នេហា

បទភ្លេងបរទេស
ទំនុកច្រៀង ៖ ស៊ីច សុន

ច្រៀងដោយ ៖
រស់ សេរីសុទ្ធា

១— ឱ! ស្នេហា-ស្នេហា ខ្ញុំខ្វាចចិត្តប្រែវាចា ចោលឲ្យទៅកំព្រាក្រែង
តែថ្ងៃក្រោយផ្លាស់ប្ដូរមិនទៀង ទឹកភ្លៀងមិនទៀងទាត់ឡើយ ។

បន្ទរ– រដូវក្ដៅក៏មិនអាចត្រជាក់ ឆ្នាំក្រោយឆ្នាំនេះក៏មិនដឹងថា ស្នេហ៍ហ្នឹង
បានឡើយ ។

២— ឈប់ងងឹតឈឹង គ្មានរស្មីច័ន្ទ ព្រោះពពកបាំងខ្យល់មិនបក់បោក ខ្ញុំ
រស់តែម្នាក់ឯង ដូចទូកកណ្ដាលទន្លេ គ្មានទីដៅ ។

(បញ្ចប់)—... ចិត្តស្នេហា កុំប្រែចិន្ដា ស្នេហា ស្នេហាខ្ញុំ ។

Slow RoCk—
DDI DoC4- B1B1 C4- CC1 C4C2 B1B1B2 C4C C4 C2C C4 B1B-
B1Bo-B1 B1C2 II

R — Co- CoC4 C4C B1Bo - C4C C4C4 B B II C4C4 B1B C4C2
B1B1 B1C- C4C B1B1 C4C- C4C II

# បងពិតជាស្ម័គ្រ

បទភ្លេង បរទេស ច្រៀងដោយ :

ទំនុកច្រៀង : **ស៊ីវ សុន** **ស៊ីន ស៊ីសាមុត**

១_ បងពិតជាស្ម័គ្រវរលក្ខណ៍ អូននាងកុំសង្ស័យ បើអូនមិនជឿបង ស្បថជូនថ្លៃ សូមពៅប្រណី ព្រមស្នេហ៍បងទៅ ។

២— បងពិតជាស្មោះចំពោះស្រី មានព្រះជាសាក្សី បងនឹងសច្ចាជូនកែវពាលពៅ ជាតិនេះខ្វះស្រីបងក្ស័យហើយ ។

បន្ទរ—ស្រីអើយស្រីស្រស់អូនកុំ កុំប្រកែកណាមាសស្នេហ៍ ពេលឥឡូវស្តាប់បងអង្វរ អង្វរសិនណាព្រលឹង ។

៣— មើលទៅព្រះច័ន្ទរះនៅខ្ពស់ ខ្ពស់ហួសនិស្ស័យ តែរស្មីនៅមាន ពន្លឺភ្លឺស្រស់ថ្លា សូមពៅអាណិតដល់ចិត្តស្នេហា ។

(បញ្ចប់)- ដែលប៉ងស្នេហ៍ ស្មោះស្ម័គ្រពិត . . . ។

**RUMBA LENT—**

B1B1B-C4C4 C4C , 4-B1Bo C4C2 C4C2 III B1B2-DoC4 C4C4 C1C4C- { B1 B1B1 BoC4CB1 IV
B1 B1B1B4 - C4CB IV

**R—** B1B C4Co-C4C- BDo- C4C2C4 B1B1B1B4-B1Bo - B1 - C1 - C1B1 DoC4 C4C2 III coda- B1B1A1-C4C2 CC CC CC III

# បើស្រីស្លរកុក

REAMVONG

F 4/4



# បើស្រីស្ងួរកុក

បទភ្លេង : **ស៊ីន ស៊ីសាមុត** — ច្រៀងដោយ :

ទំនុកច្រៀង : **ញ៉ែម ផុន** — **ស៊ីន ស៊ីសាមុត** និង **រស់ សេរីសុទ្ធា**

ប្រុស- បើស្រីស្ងួរកុកស្ងួរនឹងទឹកថ្លា ដ្បិតកុកវាថាសាច់វាស្អាតណាស់ ទាំងរោមទាំងស្លាបខ្ពស់ទាបស្ដើងក្រាស់ កុកស្គមហើយចាស់ ប្រមះស្នេហ៍ខ្ញី ។

ស្រី- អធិដ្ឋាកុកកម្មកុកចាំត្រពាំង កុករដូវប្រាំងស្គមស្គាំងរីងរៃ អូនសូម ថែទុកបញ្ចុកចំណី ថ្នមកុកកវីគ្រាន់ស្ដីឲ្យស្លាប់ ។

ប្រុស- បើកែវអាណិតកុកពិតផងរស់ សាងស្នេហ៍ដោយស្មោះមានឈ្មោះ កុកសាប់ បើកែវព្រាត់កុកនោះ មុខជាស្លាប់ ផិតឆ្ងាយយូរឆាប់ ចាប់ទាល់តែបាន ។

ស្រី- បើកុកជាប់ផុងក្នុងទ្រុងវាសនា អូនព្រមស្នេហា មេត្តាប្រោស ប្រាណ ដោះលែងសត្វកុកទុកក្នុងវិមាន ពាក់កងចិញ្ចៀនបង្រៀន ច្រៀងរាំ ។

**Ream Vong –**

B4B4-CB4 B1B II A1B-B1 B4B B1B4 II B4B4 - CB4B1B II A1B-B1 B4B B4B4 II CC C1C4 B4C C1 - CC4 II B4C1 CB4 II CCC1 C4B4 CC1-CC4 II B4C1CB4 II

# ខំផ្គាប់ប៉ុណ្ណឹងហើយ

បទភ្លេង ប្រជាប្រិយ៍ សម្រួលតន្ត្រីដោយ ៖ **កែវ ឯម**

ទំនុកច្រៀង ៖ **ញ៉ែម ផុន** ច្រៀងដោយ ៖ **សូ សាវឿន**

១— ចិត្តអើយចំបែងថ្លែងមិនអស់ ព្រោះព្រាត់ពីប្រុសគូស្នេហា ស្រណោះ
ថ្ងៃមុនគេងគន់ភក្ត្រា ថ្ងៃនេះឃ្លាតឃ្លាចោលស្រស់ស្រី ។

២— ស្រណោះម្រាមដៃបីត្រកង អូនគេងអែះខ្នងផ្គាប់ចិត្តប្ដី ថ្នមពីព្រលប់
ទល់រាត្រី ខំយកចិត្តប្ដីទាំងថ្ងៃយប់ ។

៣— ធ្លាប់គេងធ្លាប់គងធ្លាប់កៀកកើយ ផ្គាប់ប៉ុណ្ណឹងហើយនៅមិនគ្រប់
ទាញដៃចូលមុងពីព្រលប់ ផ្គាប់ថ្ងៃផ្គាប់យប់គ្រប់វេលា ។

៤— ប្រឹងផ្គាប់ណាស់ដែរតែមិនគ្រាន់ ប្រឹងដល់ប្រច័ណ្ឌខ្លាចបែកគ្នា
អូនខ្លាចមេម៉ាយព្រៅកំព្រា ខ្លាចប្រុសគ្រប់គ្នាគេមើលងាយ ។

៥— អូនគេងម្នាក់ឯងវែងខ្លោចផ្សា ខ្វះដៃសង្សារមកថ្នមកាយ ទឹកឡើង
ឆ្អែតចិត្តទ្រូងស្ទើរធ្លាយ ព្រោះប្រុសឃ្លាតឆ្ងាយផាច់មេត្តា ។

៦— តើថ្ងៃណាទៅពៅវិលវិញ ចិត្តនៅទន្ទេញឈ្មោះស្នេហា វិល
មកភ្ញាម ៗ ទៅម្ចាស់ចិន្ដា ពេលអូនរងាររារែកបង ។

**SARAVANN—**

**Co Co C4 C4-Co II CoC2 CoC.Co IV C2 B4CCoC2-B4 II B5 B4B2 BoB2 IV B4B4B4C III B5B4 B2B1B2 IV B4C CoC2-B4 II B4B2 BoB1 A4 IV**

# ស្ន៏គ្រមួយជីវិត

បទភ្លេង បរទេស — ច្រៀងដោយ :

ទំនុកច្រៀង : ញ៉ែម ផុន — ស៊ីន ស៊ីសាមុត និង ប៉ែន រ៉ន

ស្រី— វាយោត្រជាក់ ធ្លាក់មកពីឆ្ងាយ ទឹកហូរអន្លាយហូរទៅសែនឆ្ងាយ សន្ធឹម តន្ត្រីធម្មជាតិ ឆ្លៀតថ្ងូរគ្រហឹម ច័ន្ទរះមកបំព្រឹម ហាក់ប្រឹងញញឹមរកស្រី ។

ស្រី— អូនទៅចាំបង ទួនល្អងឆ្មើមចិត្ត អារម្មណ៍អូនគិត ខ្លាចបងស្នេហ៍តែសំដី ខ្លួនពេញក្រមុំកំពុងពេញវ័យ តែអូនមានចិត្តភក្តី ស្ម័គ្រស្មោះលើថ្ងៃតែមួយ ៗ

ប្រុស— បារម្ភអ្វីអូន មាសស្ងួនបណ្ដូលជីវិត បងមិនក្បត់ចិត្ត ពិតជាមិនឲ្យអូនព្រួយ បងថ្នមមាសស្នេហ៍ បងថែរជាពន្លកត្រួយ ស្នេហ៍យើងតែមួយ ឈប់ព្រួយរឿងបងបានថ្មី ។

(ពីរនាក់)— ទឹកដីព្រៃខ្យល់ យល់ហើយជួយចាំ សូមជួយចំណាំបណ្ដាំ ទុកជាសាក្សី ថាចិត្តយើងស្មោះ លុះត្រាតែក្ស័យ បើកើតជាតិថ្មី ប្រាថ្នាសុំជួបម្ដងទៀត ។

**KRONT JONG—**

B2B2B4C IV C2D C4C2 IV C2Co CB4 II { CCoC2B4CoC IV
{ CCo C2B1 B4B2 IV

R — DoDoDoD2 II DoD C4C2 CoC C4C2 IV [ C2C1C2C4 II C2B4
CC2C IV
C2CoCB4 II CC2C2
B1B4 B2 IV

# គ្រាន់តែឃើញ

SLOW ROCK

Dm



3ˉ 3 43 | 2 . . . | 0 21 7 61 | 3 . . . | 0 21 7 6 |

7. 7ˉ7. | 0 76 #5 67 | 6 . . . | 0 12 17 65 | 4 . . . |

0 21 7 61 | 3 . . . | 0 21 7 6 | 7. 7ˉ7. | 0 76 #5 67 |

6 . . . | 𝄽 𝄽 𝄽 𝄽 | 15 ... 3 |

# គ្រាន់តែឃើញ

បទភ្លេង ADAMO
ទំនុកច្រៀង : **គឹម សំអែល**

ច្រៀងដោយ :
**ស៊ីន ស៊ីសាមុត**

គ្រាន់តែឃើញស្រីម្តង ចិត្តបុំនប៉ងជាតួវាសនា តែមិនហ៊ានវាចា ខ្លាចដីវ៉ាអូនមិនប្រណី ។ ល្អខ្លាំងណាស់គ្មានអ្វីផ្ទឹម ភ័ក្ត្រញញឹមស្រស់ប្រឹមប្រិយ៍ នៅក្រោមមេឃនិងលើដី មានតែស្រីល្អផាច់គេ ។ បើសិនជាវៀមមានវាសនា បានដីវ៉ាជាគូស្នេហ៍ រៀមបីបមថ្នមបំពេ ឲ្យមាសស្នេហ៍ពេញចិត្ត ។

និយាយ- តើបុរសណាទៅ ដែលមានសំណាងបានស្រស់ស្រីពៅមកថែបនិត្យ ជាតួវាសនា ។

គន់មើលយូវីតតែស្រស់ សមឥតទាស់គាប់នេត្រា ស្រីទាំងអស់ក្នុងលោកា គ្មានស្រីណាល្អដូចទេ ។ បើសិនជាវៀមមានវាសនា បានដីវ៉ាជាគូស្នេហ៍ រៀមបីបមថ្នមបំពេ ឲ្យមាសស្នេហ៍ពេញចិត្ត ។

Boléro—

C4DDoD-C4 II CCCo CB4 B3B4 IV C4DC4C3-C3 II CCC B4B2 B1B2 IV CCC Co CB4 IV D2 DoD C4 DoC IV D2 DoDC4D-D II DC4C3C4 DC4 IV

SLOW ROCK — DoD2Do DC4 C2Co IV D2 DoD C4 DoC IV D2 DoDC4D-D II DC4C3 C4 DC4 VII

# តើឱ្យរៀមភ្លេចម្ដេចបាន



# តើឲ្យរៀមភ្លេចម្ដេចបាន

បទភ្លេងបរទេស — ច្រៀងដោយ :

ទំនុកច្រៀង : **គឹម សំអែល** — **ស៊ីន ស៊ីសាមុត**

១- តើឲ្យរៀមភ្លេចម្ដេចបាន បើកល្យាណស្រស់ម៉្លឹងៗ ស្រស់ណោស់ពេលដែលអូនខឹង សម្លឹងរៀមរ៉ា ។

២- តើឲ្យរៀមភ្លេចម្ដេចបាន បើកល្យាណស្រស់ដូចផ្កា រៀមសែនរន្ធត់ចិន្ដា ពេលណាឃើញស្រី ។

បន្ទរ- ស្រឡាញ់ម៉្លេះទេ ស្និទ្ធស្នេហ៍មេត្រី រៀមចង់ថ្នាក់ថ្នមបមបី ក្នុងន័យស្នេហា ។ សូមអូនអាណិត ដល់ចិត្តខ្ញោចផ្សា ដែលតែងចាំព្រេងវាសនា ជួបជីវ៉ាស្រី ។

៣- តើឲ្យរៀមភ្លេចម្ដេចបាន ភ្លេចកល្យាណពីគ្មានន័យ ជាតិនេះប្រាថ្នាតែស្រី ជាកំពូលស្នេហ៍ ។

៤- តើឲ្យរៀមភ្លេចម្ដេចបាន ទោះកល្យាណបានទៅគេ ក៏រៀមនៅស្ម័គ្រនៅស្នេហ៍ តែរូបស្រីមួយ ។

**SLOW ROCK –**

D1D1DC4-C1C1 II B4B4B 4 C C1C1 IV BB3CB4 -
A5A3A1 II { BBB1B3 IV / A1A5 B1B4 IV }

R—CB3 B1B B3 IV C4C1 CB4 C1 IV CDC4D1 -
CC II { B3B3-B3B1 IV / CC3DC4 IV }

# តាំងពីបានជួប




5 . 3 | 5 . . . | 05 53 53 56 | 632 1 . . | 03 21 2 3 | 6 . . 65 |

6 . 5 5 | 3 . . . | 6 . 5 2 | 1 . . . | 01 26 1 6 | 3 5 . 56 |

3 . 32 31 | 2 . . . | 0 5 5 6 | 1 . 1 2 | 6 . 6 5 | 3 . . . |

# តាំងពីបានជួប

បទភ្លេង-ទំនុកច្រៀង : **គីម សំអែល**

ច្រៀងដោយ : **រស់ សេរីសុទ្ធា**

១- តាំងពីបាន ជួបប្រុសកល្យាណជាគូស្នេហ៍ អូនសែនសប្បាយ ម្ល៉េះទេ ម្ល៉េះទេ ណាស្នេហ៍ស្នង ។

២- ស្រឡាញ់ណាស់ មិនចង់ឲ្យប្រាសប្រាណពីបង សូមចិត្តអាណិត អូនផង អូនផង ណាបងណា ។

បន្ទរ- សព្វថ្ងៃនេះមានតែប្រុសអ្នក ដែលអូនស្ម័គ្រស្មើសង្ខារ ឥតគេចឥតកែ ប្រែសាវា ទេណាបង ។

៣- សូមទេព្តា ជួយថែរក្សាស្នេហ៍ខ្ញុំផង ឲ្យបានឋិតថេរយូរលង់ យូរលង់ អង្វែងអើយ ។

**Boléro—**

C2 - CC2 IV C4C2 CC2 CC2 C4CB4B2 IV CB4 B2B4 CB II C4

C2C4- { C2C2C V
{ C2B4B2 IV

R — B2B4 BB2 BCC2 II C2 C4C-CB4C B2B4 IV A4A4 BB2-
B2B4B-C4C2C V

# ដងស្ទឹងស្នេហា

បទភ្លេងបរទេស — សម្រួលតន្ត្រីដោយ : សម សាខន

ទំនុកច្រៀង : វ៉ៀម ផុន — ច្រៀងដោយ : រស់ សេរីសុទ្ធា

១— ពេលបានជួបបងនៅតាមដងស្ទឹងស្នេហា ចិត្តអូនប្រាថ្នាតិតថាជាព្រេងនិស្ស័យ ពាក្យសម្បថបានកំណត់ជាសាក្សី ចិត្តភក្តីឥតមានប្រួលប្រែ ។

២— អូនបានជួបបងនៅតាមដងស្ទឹង ស្នេហា ផ្គោះផ្គងវាចាចិន្តាថាមិនបែកបែរ ចិត្តក្រមុំអង្វរលន់តួសុំស្នេហ៍ ខ្លាចប្រុសប្រែតេចកែសំដី។

បន្ទរ– ទឹកហូរឆ្ងាយហើយ ហូរនាំចម្លើយទៅឆ្លើយប្រាប់ដល់ប្រុសថ្លៃ សូមបងប្រណីមេត្តាដល់ស្រី ដែលបេតី ហ៊ា ហ៊ា ហ៊ា លើរូបបងប៉ងក្នុងចិត្ត ។

៣- អូនបានជួបបងនៅតាមដងស្ទឹង ស្នេហា ប្រគល់វាសនា សង្ឃារ សូមបងអាណិត ទឹកស្ទឹងអើយកុំព្រងើយនូវរឿងពិត ហូរនាំចិត្តប្រុសជួបអូនផង ។

(សង្វាក់ Boléro Lent)

# រដូវភ្លៀងធ្លាក់

បទភ្លេង បរទេស ច្រៀងដោយ :

ទំនុកច្រៀង : **ស៊ីន សុន** នាង **ម៉ែន រ៉ន**

១- រដូវភ្លៀងធ្លាក់ ត្រជាក់រងា សព្វអង្គកាយា ឲ្យនឹកម្ល៉េះទេ ក្នុង
ចិត្តគេងក៏ពុំលក់ ខ្វល់ចិន្តា ។

២- ព្យុះសន្ធឹកបោកបក់មកយ៉ាងខ្លាំង អូននៅតែចាំ ស្នេហាទ្រូងរណ្ដំ
ខ្លោចផ្សា ចិត្តនឹកដល់ថ្លៃ គ្មានភ្លេច ។

បន្ទរ- ធ្លាប់ក្រសោបអោបត្រកង ថ្នាក់ថ្នមបី ម្ដេចប្រុស ថ្លៃគេចញ្ជើជីវិតចិត្ត
ស្នេហ៍ ទុក្ខព្រួយ ។

៣- ខ្ញុំមិនចង់នៅរស់នាំខ្មាស់គេ ស្លាប់ចុះមិនចង់យល់ទេ ស្នេហ៍
អប្រិយ៍ បិទភ្នែកឲ្យក្ស័យ នៅរស់ធ្វើអ្វីចង្រៃលោក ។

**Bostom** -

B1B1 - B1B4Bo - B4C2 - B1B4 - B1B2 CoC2 C4C2 - B1B4 B4Co

C2C- { B4C II C4C2 III
B4C II C4C III

R — DB- C4C2 C4B1B1 Co C2C2 II B1 C2CCB1 B2C4 B1B

C4C4- IV

# ក្រមុំរើសប្តី




31 11 | 1. 7 | 76 56 | 7_ | 31 1_ |

11 4 | 32 17 | 17 6 ⌒ 6_ ⌒ 66 54 |

6 .6 ⌒ 66 54 | 2 31 ⌒ 13 46 | 3_ _ |

3_ _ _ | 3 12 | 3 12 | 36 53 | 3_ _ |

21 33 | 3 _ _ | 21 23 | 3 3 | 4 6 | 6 ⌒ 6 |

# ក្រមុំរើសប្តី

បទភ្លេង បរទេស

ទំនុកច្រៀង : **អឹម សុខសីម**

ច្រៀងដោយ :

**អឹម សុខសីម** និង **ម៉ែន រ៉ម**

ស្រី— ខ្ញុំឃើញគេរៀបការ ចិត្តចង់តែរៀបការដែរ តែ ៗ គ្មានប្រុស ណាៗ គួរឲ្យពេញចិត្តសោះ ។

ស្រី— ប្រុសខ្លះស្រឡាញ់ខ្ញុំ មើលចិត្តបែបជាមិនស្មោះ ប្រុស ៗ ខ្លះចិត្ត ស្មោះ តែសម្រស់មិនបាន ។

ប្រុស— ចុះតើកម្មអ្វីនាងក្រមុំរើសប្តី មិនបានខកប្រាណកចង់យំ ...

ស្រី— ស្រឡាញ់បងនេះ ហើយបងនោះប្តីគេទាំងអស់ អស់សង្ឃឹម ហើយខ្ញុំ ៗ ក្រមុំរើសប្តី ។

ប្រុស— បងទៅ ! ...

**SAMBA —**

B4C1 C1C1C1-CCB4B4 B4C-B4C1 C1C1C1-DC4C2-C4C2C1C1-B4- IV (Bis) D2C4DD2 D2-D2C2DC1C4C1 - C4DD2C4-C4C1 C2C1 C2C4 D2D2 DC4- C2C1C2C4 C4 C1C2C4C1- C4D D1D2-

# ខ្យល់ត្រជាក់

បទភ្លេង បរទេស

ទំនុកច្រៀង : ស៊ីុច សុន

ច្រៀងដោយ :

ស៊ីុន ស៊ីសាមុត

១— ឱ! ផ្ទៃមេឃស្រឡះភ្លឺថ្លា ពន្លឺសោភាស្រស់ត្រចង់ ផ្ការីកល្អូតលោស់
 រហង់ រហង់រីកស្រស់បំព្រង តើចាំអ្នកណា ។

២— ខ្យល់បក់បកត្រជាក់ក្នុងចិត្ត ចិន្តាខ្ញុំគិតដល់ជីវ៉ា ក្រអូបក្លិនស្រីរសាត់
 តាមខ្យល់ ធ្វើឲ្យខ្ញុំខ្វល់ព្រោះក្លិនស្នេហា ។

បន្ទរ— ខ្យល់អើយខ្យល់ត្រជាក់ រសាត់បកថ្នាក់ថ្នមសព្វកាយា ចិត្តរំភើប
 ស្រៀវស្រើបចិន្តា ពេលណាថ្ងៃណាបានផ្កាមកក្បែរខ្ញុំ ។

៣— រាត្រីនេះរាត្រីស្អែក ផ្កាកុំប្រកែកខ្ញុំក្រៀមក្រំ អាសូរដួងចិត្តកំព្រា
 ច្រើនឆ្នាំ ព្រោះតែរង់ចាំទទួលក្លិនផ្កា ។

**Slow Rock—**

C4C4 C4C4- C4B1B4 II B1B1-C4-C2C2 C4C2 C4C C4C2- CB1

CoC4- { C4C-C4C III
{ C4C-C4C2 III

R— C4-C4-CoCoB1 B1B C4C2 C4CB C4C2 - C4-C2- CC1 C2C

B1B- C4C III

# បទសុំផ្ញើស្នេហ៍

បទភ្លេងថៃ — ច្រៀងដោយ :

ទំនុកច្រៀង : **ស៊ីន សុន** — **មាស សាម៉ន**

១— អាឌុឌី អាឌុឌី ឃើញស្រីល្អ ស្រីល្អដូចៗគ្នា អូននឹងបងអ្នកផង ចោមមើលចង្កេះស្រីតូចរាងរៀវ មើលចំសមអីម្ល៉េះទេ បងចង់តែរួម ស្នេហ៍និងស្រី (មិនចង់ឲ្យឃ្លាតឆ្ងាយមួយវេលាណា(ពីរដង)...) សូម អូនមេត្តាស្រឡាញ់បងទៅ ។

២— អាឌុឌី អាឌុឌី ស្រីរូបល្អសាច់សដូចចាន បានមកជួបនឹងប្រុសចិត្ត មួយ សូមស្រីកុំព្រួយណាស្រស់កុំផាន ស្មគ្របងៗនឹងចូលស្ដី ចូលស្ដីយកស្រីជាគូស្នេហា (បងនឹងរៀបការជាមួយស្រស់ស្រី (ពីរដង)..) សូមពៅកុំភ័យណាកែវដីរ៉ា ។

បន្ទរ– ក្រូចសើចផ្លូវយកក្រូចឆ្មា ស្នេហាផ្លូវយកស្នេហា អោរ៉អោរ៉ាចង់ ឈ្មុះកូនប្រសារ គ្មាននរណាទាក់ទាម ម៉េចក៏ស្ងៀមអាហ៊ុស្រី ៗ គូនិងប្រុសៗ ហ៊ា ស្ម័គ្រឬក៏មិនស្ម័គ្រ បងស្ម័គ្រតែស្រីចិត្តមួយ ។

៣— អាឌុឌី អាឌុឌី ណងកាប់គីរ៉ាន់ឌុឌីកាន់ដៀវ ផ្ទះបងនៅឆ្ងាយពីស្រី ផ្ទះស្រីថ្ងៃនៅក្បែរគុម្ពោត ពោះម៉ាយសមគ្នាណាស់ ពងមាន់ គូនិងពងទា ( បងសុំផ្ញើស្នេហ៍ធ្វើប្ដីស្រីហើយ (ពីរដង)...) បើអូន ចិត្តបុណ្យព្រមស្ម័គ្របងទៅ ។

**Ream Vong—**

B1B1 B1C4 C4C-C4 B1B-C4 IV C4C II C4C C4C C4C-C1C2
C2C4 B1B C4C-C4B1- B1B C4C B1B2 C4 -

# ចោរចិត្តជា

CHA CHA CHA D 2/4



5 13 5 6 | 03 63 5 0 | 05 13 5 6 | 03 63 2 0 |

01 35 6 5 | 05 67 6 0 | 03 67 6 0 | 05 55 5 32 |

2 . . . | 05 55 3 2 | 2 26 1 . | 01 71 2 . 1 |

5 . . . | 06 66 2 35 | 2 . . 3 | 3 1 3 . 5 |

6 . 0 3 33 | 3 . 6 1 . 2 | 3 . . . ||

# ចោរចិត្តជា

បទភ្លេង បរទេស　　　　　សម្រួលតន្ត្រីដោយ : **សម សាខន**

ទំនុកច្រៀង : **ញ៉ែម ផុន**　　　　　ច្រៀងដោយ : **ស៊ីន ស៊ីសាមុត**

១— ប្រុសគេដទៃស្រីប្រឹងចោមស្រឡាញ់　　ប្រុសខ្ញុំស្រីចោមខ្ទាញ់លួចស្អប់គ្រប់គ្នា　　គេចោទប្រុសខ្ញុំទុកស្មើនឹងអ្នកងា　　ទ្រូងដាំត្រាំត្រាព្រោះស្នេហា ។

២— ចោរលួចរបស់ព្រោះចង់ធ្វើអ្នកមាន　　ចោរខ្ញុំមិនហ៊ាន　　ព្រោះខ្លាចមានទោសា　　ចោរខ្ញុំចិត្តជាលួចត្រឹមតែស្នេហា　　លួចមើលភក្ត្រាស្រស់ពីសិ ។

បន្ទរ— ខ្ញុំធ្វើចោរដែរតែចិត្តជា　　មាននាមនឹងងារជាកវី　　ចិត្តគួចលួចបេតីលួចច្រើនខែថ្ងៃលួចស្នេហា ។

៣— មិនដែលបានសោះព្រោះខ្ញុំមិនសូវហ៊ាន　　តែនឹងលួចបំពានអៀនម្ចាស់ចិន្តា　　បើប្រែមានទោសតើធ្លាក់ដល់ត្រឹមណា　　បើចោរលួចស្នេហា　ចោរដួងចិត្ត ។

CHA ! CHA ! CHA ! —

AB B3C C1-B3C1 B3 - AB B3C C1-B3C1 B3B1- BB3 CC4 C3-
CC1 C3C1- { CC CC B3 B1B3 IV
　　　　　{ CC CB3 B1- A2B IV

R— C4C3 C4D- C4C IV C1C1 C1C1 B3 CB1 II B3 B1 BB3-
CC1 II B1B1 B1B1-A2B-B1B3 III

# ព្រហ្មលិខិតកំណាច

បទភ្លេង-ទំនុកច្រៀង :
ស៊ីន ស៊ុន

ច្រៀងដោយ :
ស៊ីន ស៊ីសាមុត

១— រយម៉ឺនចិត្តស្ត្រីដែលអស់សង្ឃឹម ពួនមុខលែងញញឹម ចុកចាប់ឱរ៉ាយំ
ដែលស្រែកបន្ទោស ព្រហ្មលិខិតកំណាចឬស្យា បំផ្លាញស្នេហាខ្ញុំ ។

២— នេះហើយឬវណ្ណៈទឹកប្រាក់និងមាស ចាប់រូសដែលញៀសចេញ
ទាំងបង្ខំ គេពោលចំអកឡកឡឺយនឹងខ្ញុំ គេវាយគេដំ ព្រោះគេ
លែងស្នេហ៍ស្និទ្ធ ។

បន្ទរ- ខំផ្តាច់និស្ស័យចង្រៃចិត្តបរិសុទ្ធ នៅតែក្រាបលុតឲ្យគេរារាំណិតតែ
ឈាមខ្មៅ គ្មានធម៌ខ្វះចិត្ត ឲ្យជីវិត ប្រែជាងងឹតឥតន័យ ។

៣— ឱ! មេឃមីរខ្ទាញ់ក្តាម បណ្តាំាស្ងួរិយា លាភពពសធារហោស៍ស្រី
ព្រឹកព្រៃដូចខ្ញុំ ព្រាត់ស្នេហ៍ទាំងក្តីអាល័យ ខ្ញុំលាទៅក្បៀយ ឆ្ងាយ
ពីលោកនេះហើយ ។

**Boléro Lent—**

C C2B4·B2B4 CC4 C2C - B B1B A4B2 B4B-A4A2 II BB AB1

B4B A2A4C4 oC2B4 { B2- B4 B2C B4B4 II
{ B2-B1 BA4 BB II

R - A4B B2A2- A4B B2B4 CC2- CC4-DoC2C4 DoC C2C4 II

B2 B4C B2 B4 B2 B- A2A4B CC2 CB B2B4 II

# ចៅព្រាហ្មណ៍

បទភ្លេង បុរាណ

ទំនុកច្រៀង : **ស៊ីន ស៊ីសាមុត**

ច្រៀងដោយ :

**ស៊ីន ស៊ីសាមុត**

១— ឱ! ណាចៅព្រាហ្មណ៍អើយ ណ្ដើយកុំតូចចិត្ត ( ពីរដង ) បើគេមិនអាណិត ចិត្តគេដោយខ្លួន ឱណាកែវណានាងណា ចិត្តគេដោយខ្លួន ។

២— ស្នេហ៍គេគួរតែ គេខំថែធ្លួន (ពីរដង) ធ្វើម្ដេចកម្មខ្លួន កើតមកខ្វះស្នេហ៍ ឱណាកែវណា នាងណា កើតមកខ្វះស្នេហ៍ ។

៣— ណ្ដើយស៊ូនៅព្រៃ តាមកម្មបុព្វេ ( ពីរដង ) បើគ្មានគេស្នេហ៍ គឺកម្មព្រាហ្មណ៍ឯង ឱណាកែវណានាងណា គឺកម្មព្រាហ្មណ៍ឯង ។

**( បទបំពេបុរាណ )**

# សម្លេងស្គរដៃឯក


ROCK
D 4/4
Solo Batterie
0 5 6 5 i i 6 5
3 . . .
0 2 3 5 3 2 1
2 6 . .
0 1 1 2 3
5 5 . .
5 5 6 6 5 2 i 7 6
5 . . .
0 5 6 5 i i 6 5
5 5 6 5 2 7 6 5
i . . .
Solo Batterie
0 i 6 i 6
0 i 6 i 6
0 i 6 5 6 i
0 i 6 5 i 6
0 i 6 i 6
0 i 6 i 6
0 i 6 5 i i
0 0 i 6 5
5 . . .
Solo Batterie
0 5 6 5 i i 6 5
3 . . .
0 2 3 5 3 2 1
2 6 . .
0 1 1 2 3
5 5 . .
5 5 6 5 2 7 6 5
i . . .
Solo Batterie
0 5 6 5 i i 6 5

# សម្លេងស្គរដៃឯក

បទភ្លេង បរទេស
សម្រួលតន្ត្រីដោយ : **សម សាខន**

ទំនុកច្រៀង : **ញ៉ែម ផុន**
ច្រៀងដោយ : **ស៊ីន ស៊ីសាមុត**

១— ឮសម្លេងស្គរហោក់ញ័រអស់ប្រាណ ចិត្តខ្ញុំប៉ុន្មានរំភើបឡើងយ៉ាងខ្លាំង
ឮសម្លេងស្គរក្តុងក្តាំង ចិត្តស្ទើរភ័ន្តភាំង តាមសង្វាក់ភ្លេង ។

២— ពេលខ្ញុំវាយស្គរត្រេកអរខ្លាំងណាស់ ស្នូរដូចរន្ទះសន្ធឹកស្នូរគគ្រេង
ខ្ញុំវាយបន្ទរតាមភ្លេង ខ្ញុំច្រៀងខ្ញុំលេងតាមចិត្តខ្ញុំស្ម័គ្រ ។

បន្ទរ– សាំបា សាំបា សាំបា សាំបា សូមរាំជាមួយស្គរ ខ្ញុំបន្ទរតាមអ្នក
ឆាំបា ឆាំបា រាំជាមួយសង្វាក់ខ្ញុំសូឡូស្គរ ។

៣— ខ្ញុំច្រៀងតាមភ្លេងលេងតាមសង្វាក់ អ្នករាំញាក់ទៅតាមនឹងបទ
ភ្លេង រាំលេងតាមសង្វាក់ស្គរ ខ្ញុំវាយបន្ទរតាមរបៀបថ្មី ។

FOX—

CC1 CC4 C4C1 CB3 IV B1B3 CB3 B1F B1-A1 III B BB1B3
C IV { CC1 CD C4C3 C1C IV
CC1 CD C4C1 CC4 IV

R— C4 C1C4 C1-C4C1C4 C1-C4 C1C C4C4-C4 C1C4C1-C4 C1C4
C1-C4 C1C4C1-C4C1C4C4-C4C1 B3C IV

# ដូចមិនមែនខ្ញុំ

បទភ្លេង បរទេស          ច្រៀងដោយ :

ចំនុកច្រៀង : **អ៊ឹម សុខសីម**          **អ៊ឹម សុខសីមនិងរស់ សេរីសុទ្ធា**

ស្រី— នែ! ប្រុសនេះ មកពីណាហៅគេផងទេតើ បងស្គាល់ខ្ញុំពី
កាលណា? ..

ប្រុស— ម៉េចចឹងអូនស្រី ក្រែងអូនថាស្រឡាញ់បង ព្រោះផ្ទះអូនផ្ទះបង
ធ្លាប់នៅជិតគ្នា ថែមទាំងមានសំបុត្រ សរសេរឆ្លើយឆ្លងស្នេហា
ឥឡូវមាសមេបែរជាកែប្រែហើយធ្វើមិនស្គាល់ ។

ស្រី— នែ! ប្រុសនេះមកពីណាហៅគេផងទេតើ បងស្គាល់ខ្ញុំពីកាលណា?

ប្រុស- ឈប់សិនអូនស្រី ប្រញាប់អីអូនស្ដីឲ្យបង បានជាខុសម្ដងធ្វើឲ្យ
បងខ្មាសគេ អូនមានឃើញទេគេសើចគ្រប់គ្នា ។

ប្រុស- ថ្ងៃនេះបងស្លៀកពាក់មិនហ៊ឺហា បានជាធ្លោយឲ្យភ្លេចមុខ ភ្លេច
ក្រោយ ឲ្យភ័ណ្ឌច្រឡំ មើលអាវខុស ស្បែកខុសនេះហៅចំ
ខោរហែកវែនតាបែកដូចមិនមែនខ្ញុំ ។

**JERK —**

BC1 C1C1C1 - CB4 CB4 C1CC- B1B4CC1C B4CBB-C1C1C1C1-
CB4C B4C1CC-B1B4CC1 CB4CB B- ( BiS )   CB4 C1C1 C1C2
C1C- CC1 CC1CB4C1- C1C1 C1C2 C1C- CCCC1 CB4C1 -
CCCC C1C. IV

# មិនទាន់ពេញចិត្តទេបង

បទភ្លេង បរទេស ច្រៀងដោយ :

ទំនុកច្រៀង : អឹម សុខសីម អឹម សុខសីម និង រស់ សេរីសុទ្ធា

ប្រុស- ពេលបានឃើញមុខអូនភ្លាម ចិត្តបងប៉ងតួចស្នេហា តែបងមិនដឹងចិត្តស្រីនាងគិតយ៉ាងណា ចំណែករៀមបងពេញចិត្តស្រឡាញ់គ្រប់វេលា ។

បងច្រៀងថ្នាក់ថ្នមស្នេហា បំពេឲ្យគេងតើព្រលឹងពេញចិត្តទេ ។

ស្រី- មិនទាន់ពេញចិត្តទេបង! . . .

ប្រុស- តើព្រលឹងត្រូវការយ៉ាណា? . .

ស្រី- ស្អីក៏បានដែរបង ! . . .

ប្រុស- យប់ណាស់ហើយអាណិតបងផង !

ស្រី- គេងមិនលក់ទេបង!..

ប្រុស- អាណិតបងផងណាព្រលឹង ។

JERK—

B4C1 C4- B4C1C4 B4C1C4-D2C1 C2C1 CB4 ( BiS ) C1C1C1C1-
CB4B ' CC- C2C2C2 C2C2- C1CB4 C4C4C4C4 ( 2C1C2C1
C4D- C4C2C1- C2C1CB4 IV

R — B4C2C4D C4C2 C2D1 D-B4C1 B4C2 C4D-C4C2 D2D C4-
C1C1C1C1- C1C2C1C- II

# ស្ដាប់បងច្រៀងបំពេ

បទភ្លេងថៃ ច្រៀងដោយ :

ទំនុកច្រៀង : **ស៊ីន សុន** **ស៊ីន ស៊ីសាមុត**

១- ឱ! ស្នេហ៍មាសបង ស្ដាប់ភ្លេងបងច្រៀងបំពេ ជាតិនេះរៀមស្នេហ៍ ស្នេហ៍អូនពិតក្នុងហឫទ័យ ពេលញាំក៏ញាំមិនបាន ពេលគេងទុក្ខ ព្រួយរាល់ថ្ងៃ ដឹងទេចរណៃ រៀមសូមស្នេហ៍ស្រីប្រាកដ ។

២- ស្រឡាញ់បងទៅ បងនឹងលើកទូលថ្នាក់ថ្នម បំពេបីបមដោមស្នេហ៍ មិនឲ្យកង្វល់ ពាក្យពិតបងពោលពាក្យពិត ចិត្តស្នេហ៍តែដោមនិមល លោកនេះលោកមុន ស្នេហ៍អូនលុះត្រាក្សិណក្ស័យ ។

បន្ទរ- រៀមនឹងថ្នាក់ថ្នមបីបមដោមកែវនិមល រៀមសុំអត់ធន់ទ្រាំទុក្ខលំបាក វីវរ គេថាផ្លូវថ្នល់ គេថារថយន្តជាតួនិស្ស័យ ដួងថៃដួងចិត្តបង ក្ស័យតាមស្រីជានិច្ច ។

៣- **ឱ!** ស្នេហ៍មាសបង បើទួនល្អងព្រមរួមប្រាណា អរណាស់ កល្យាណ បើស្នេហ៍ប្រែជាទឹកមន្ត ឲ្យក្ស័យក៏បងព្រមក្ស័យ មិន ស្ដាយជីវិតឡើយ ភក្ត្រមូលដូចច័ន្ទបងសូមរួមរ័ក្សលុះក្ស័យ ។

(សង្វាក់ Slow)

ដកស្រង់ពីខ្សែភាពយន្តថៃរឿង **ម៉ី តែងនាងហុង**

# ស្រមៃដល់អូន

បទភ្លេងថៃ
ទំនុកច្រៀង : ស៊ីទ សុន

ច្រៀងដោយ :
ស៊ីន ស៊ីសាមុត

១- ពេលព្រលឹមញញឹមនឹក នឹកដល់តែស្រី ពាក្យផ្អែមជាប់ក្នុងចិត្ត ចិត្ត
នឹកដល់ពេលថ្នាក់ថ្នម ។

២- យប់យន់សែនស្ងាត់ ស្ងាត់ស្ងួន្យ អូនភ្លេចរូបបង តែស្នេហ៍បងនៅ
តែចាំ ចាំមិនភ្លេច ។

. . . ភ្លេង . . .

បន្ទរ- ព្រលឹងមើលដួងច័ន្ទ ពន្លឺស្រទន់នៅអាកាស មេឃស្រឡះពន្លឺថ្លាច្បាស់
រស្មី ព្រះពាយរំភើយត្រជាក់ហឫទ័យ ស្រមៃដល់អូន ។

(ពីរដង)

Slow —

B - BB - C4C4 - CCC1 - C - C4C2 C4C B1B-B-BC4C2 - B1B -

B1C- { B1 BBB III
B1BBB1 II }

R— C4- CCC C C1B1 II C4C2 C4 B1B2 C4C C1B- C4C CC-
C4C- C-B1B1 C1B B1B1B1- B1B2 III

# ស្រឡាញ់បងពេក

ROCK




43 46 43 | 22 27 2. 12 72 32 72 | 6... | 0 43 46 43 |
22 27 2. 12 72 32 72 | 2... | 07 23 27 2 | 76 6 6. |
07 2 23 46 | 6... | 0 77 7 2 | i 76 i. i i 76 4. |
4 32 4. 4..32 | 73 27 6. 66 72 2. 2 000 |



# ស្រឡាញ់បងពេក

បទភ្លេងបរទេស

សម្រួលតន្ត្រីដោយ : **សម សាខន**

ទំនុកច្រៀង : **ញ៉ែម ផុន**

ច្រៀងដោយ : **រស់ សេរីសុទ្ធា**

១- នៅក្នុងចិត្តពិតជាស្រឡាញ់ តែប្រុសបងមួយ ប្រុសកុំព្រួយខ្លាចស្រីប្រែចិន្តា ចិត្តអូនស្នេហ៍ចំពោះលើបងជាសង្សារ គ្មាននរណាមកបំបែកបាន។

បន្ទរ- ខានជួបមុខទុក្ខព្រួយស្ទើរស្លាប់ ចង់រៀបរាប់ប្រាប់ប្រុសកល្យាណ ខ្លាចប្រុសស្នេហ៍ ប្រួលប្រែជាខកខាន ហ៊ា ហ៊ា ហ៊ា ហ៊ា ហ៊ា ហ៊ា ខ្លាចប្រុសបងបោះបង់ចោលប្រាណ ខានរួមវាសនា ។

២- នៅក្នុងចិត្តពិតជាស្រឡាញ់ តែប្រុសបងមួយ ប្រុសកុំព្រួយ ខ្លាចស្រីប្រែចិន្តា ចិត្តអូនស្នេហ៍ចំពោះលើបងជាសង្សារ គ្មាននរណាមកបំបែកបាន ។

បន្ទរ- អូនស្រឡាញ់ៗ បងពេក អូនចង់ស្រែកឲ្យបែកលោកា ចិត្តចំបែងប្រលែងតែទុក្ខា ហ៊ា ហ៊ា ហ៊ា ហ៊ា ហ៊ា ហ៊ា ស្រឡាញ់ពេក ចិត្តអន្ទះសា ដោយសារប្រុសស្នេហ៍ ។

Boléro —

C1 CC1 C4C1 CB4 B4-B1B4 II B1 B4C B4B1 B4B IV C1 CC1 C4C1 CB4 B4-B1B4 II B1 B4C B4B1 B4B4 IV

R— B1 B4C B4B1 B4B1 B IV B1B4B4 CC1 C4C4 IV DDD- D2D1 D1 C4D1-DC4C1 II CB4C1 IV CB4B1 CB4 B1B II BB1 B4B4 IV

# លុះផុតលោកា

បទភ្លេង-ទំនុកច្រៀង : **អ៊ឹម សុខស៊ឹម**

ច្រៀងដោយ : **អ៊ឹម សុខស៊ឹមនិងរស់ សេរីសុទ្ធា**

ប្រុស- ស្រស់អើយសែនស្រស់ សម្រស់ប្លែក បងឃើញច្បាស់ផ្ទាល់នឹងភ្នែក ចិត្តគិតហើយសង្វេគ ប្រាណចង់បានរូបរិតគៀកកើយ ។ ទ្រូងអើយរំខាន ស្នេហ៍ចិត្តបាត់មុខមិនបាន តែកល្យាណគ្មានណាយ ។

ស្រី- យូរឆាប់គង់ជួបរូបអូន ក្នុងខ្លួនមួយម៉ោខ្វល់ខ្វាយ រាល់ថ្ងៃនឹកបង តែចិត្តរង់ចាំថ្ងៃ លន់តួគ្មានស្តាយ លុះថ្ងៃផុតលោកា ។

ស្រី- ភ្លៀវៃចៃហ្វេប៉ង ជិងម៉ងម៉ាយ រូត្វរ៉ាឈួកើនប៉ៃ ខានចៃលួបលួ ប៉ៃថើ យាំងឃើ រាំភើងរាំផាន់ យ៉ាងហ្វាន់ណាងល្មើ ឃ្វាតចៃ ឆាន់ជិងណាកអើយ យៃហ្វោថើម៉ែណាយ ។

ប្រុស- មៀនជាំឆាយឈួក ង្វូកក្លោ មៀង៉ៅ មួមោម៉ៃក្វាយ វ៉ៃភៀងជិង ម៉ង មៀយៀកខង ប្រៀដាយលន់តួចុនកាយ អាយខោតួលោកា ។

(សង្វាក់ Rumba lent )

# ព្រានព្រៃក្លាហាន

បទភ្លេង បរទេស

ទំនុកច្រៀង ៖ អ៊ឹម សុខស៊ីម

ច្រៀងដោយ ៖

អ៊ឹម សុខស៊ីម

១— ខាលស្មោះដើរភ្នំសត្វឃ្មុំឆ្លងឆ្ងាយ  សត្វខ្លា សត្វរមាំងច្រើសអើយ សូមអ្នកមេត្តាចេញរួបរាងកាយ  ខ្ញុំនេះនោងនាយ  ឆ្លងព្រៃមកឆ្ងាយ  សប្បាយនឹងជីវភាព ។

២— ព្រានព្រៃខ្ញុំនេះ  គោរខ្លាខ្លាចរាប  ប្រទះខ្ញុំបាញ់ក្លាហានអីរាង ស្អប់ណាស់ស្រី តែខ្ញុំក្លាហានសុភាព  សាហាវផងខ្លា ។

( សង្វាក់ *Samba* )

# ស្រឡាញ់ពេញប្រាស

បទភ្លេងបូរាណ

ទំនុកច្រៀង :គឹម សំអែល

ច្រៀងដោយ :

រស់ សេរីសុទ្ធា

អើយ... សារាយអណ្តែត បងអើយបង សារាយអណ្តែត ត្រសែតដោយទង ។

អើយ... កំពីងពួយបង បងអើយបង កំពីងពួយបង អណ្តែតត្រសងជាប់ទងសារាយ ។

អើយ... ស្រឡាញ់ពេញប្រាស បងអើយបង ស្រឡាញ់ណាស់គ្មានណាយ បងឃ្លាតទៅឆ្ងាយឲ្យស្រីចាំបែង អើយចាំបែង ។

អើយ... ពីថ្ងៃនេះតទៅបងអើយបង អូននៅតែម្នាក់ឯង វិលវល់ដូចខ្លែង វង្វេងតាមខ្យល់ ។

អើយ... ស្តាយភក្ត្រល្អស្រស់ បងអើយបង ស្តាយប្រុសបងចេះផ្តល់សុខឥតអំពល់ មកដល់រូបស្រី អើយ រូបស្រី ។

អើយ ... ថ្ងៃណាបងវិលវិញ បងអើយបង បងទន្ទេញរាល់ថ្ងៃ សូមបងប្រណី កុំចោលស្រីយូរ ។

(បទសារាយអណ្តែត)

CEDORECK
N° 61



៣.៧- ៨.៦. ១៩៧០?

# ទំព័រអក្សរភ្លេង ទំនុកច្រៀង


| ទំព័រ | អក្សរភ្លេងទំនុកច្រៀង | ទំព័រ | អក្សរភ្លេងទំនុកច្រៀង |
|---|---|---|---|
| 1 | រស់.សេរីសុទ្ធា | 25 | តើឱ្យរៀមភ្លេចម្តេចបាន |
| 2 | នាង រ៉ែន.រ៉ន | 26 | អក្សរភ្លេង |
| 3 | ស៊ីន.ស៊ីសាមុត | 27 | តាំងពីបានជួប |
| 4 | នាង ហួយ.មាស | 28 | ដងស្ទឹងស្នេហា |
| 5 | ស្ទឹងស្នេហា | 29 | រដូវភ្លៀងធ្លាក់ |
| 6 | អក្សរភ្លេង | 30 | អក្សរភ្លេង |
| 7 | ខ្មៅអើយខ្មៅ | 31 | ក្រមុំរើសប្តី |
| 8 | កន្លង់មាស | 32 | ខ្យល់ត្រជាក់ |
| 9 | សំបួរមាស | 33 | បងសុំផ្ញើស្នេហ៍ |
| 10 | អក្សរភ្លេង | 34 | អក្សរភ្លេង |
| 11 | លិញជូមាសបង | 35 | ចោរចិត្តជា |
| 12 | បងស្រឡាញ់តែអូន | 36 | ព្រហ្មលិខិតកំណាច |
| 13 | កាលអូនស្រឡាញ់បង | 37 | ចៅព្រាហ្មណ៍ |
| 14 | អក្សរភ្លេង | 38 | អក្សរភ្លេង |
| 15 | ឃុំផ្ញើសំបុក | 39 | សម្លេងស្គរដៃឯក |
| 16 | ចិត្តស្នេហា | 40 | ដូចមិនមែនខ្ញុំ |
| 17 | បងពិតជាស្ម័គ្រ | 41 | មិនទាន់ពេញចិត្តទេបង |
| 18 | អក្សរភ្លេង | 42 | ស្តាប់បងច្រៀងបំពេ |
| 19 | បើស្រីស្តូរកុក | 43 | ស្រមៃដល់អូន |
| 20 | ខំថ្នាប់ប៉ុណ្ណឹងហើយ | 44 | អក្សរភ្លេង |
| 21 | ស្ម័គ្រមួយជីវិត | 45 | ស្រឡាញ់បងពេក |
| 22 | អក្សរភ្លេង | 46 | លុះផុតលោកា |
| 23 | គ្រាន់តែឃើញ | 47 | ព្រានព្រៃក្លាហាន |
| 24 | អក្សរភ្លេង | 48 | ស្រឡាញ់ពេញប្រាស |



រោងពុម្ព ស៊ីន-ម៉ុយ តម្លៃ ២០៛០០


គ.ស- ១៩៦០?